SOUTH AUSTRALIA POLICE
KEEPING SA SAFE

SIGNATURE SERVICE
ATTITUDE COUNTS

# ធម្មនុញ្ញនៃការផ្ដល់ជូនការបំរើ

ក្រសួងប៉ូលីសប្រចាំរដ្ឋអូស្ត្រាលីខាងត្បូងប្ដេជ្ញាដើម្បីបំរើយ៉ាងឧត្ដុងឧត្ដមក្នុងការផ្ដល់ជូនការបំរើយ៉ាងមានស្ថេរភាព គុណភាពខ្ពស់ចំពោះសហគមន៍និងប្រជាជនរបស់យើងផ្ទាល់

## នៅទីណាដែលប្រជាជនណាម្នាក់ត្រូវការ រឺ ស្វែងរកការបំរើ, យើងនឹង:

### ផ្ដល់ជូនការបំរើ យ៉ាងគួរសម, សុភាពរាបសារ និងជាទីគោរព:

- មើលថែប្រជាជនយ៉ាងគួរសមនិងជាទីគោរព
- ស្ដាប់ព្រមទាំងទទួលយកការចាប់អារម្មណ៍យ៉ាងមធ្យ័ត
- បង្ហាញការចាប់អារម្មណ៍និងទទួលរ៉ាប់រងដល់ប្រជាជន
- សុភាពរាបសារនិងចេះគិតពិចារណា
- ផ្ដល់ជូនដំបូន្មានយ៉ាងត្រឹមត្រូវ
- មានសារៈប្រយោជន៍

### ដោះស្រាយដោយជំនាញការចំពោះការសាកសួរជាលើកដំបូង:

- ពន្យល់ពីរបៀបដែលបញ្ហារនឹងត្រូវទទួលដោះស្រាយ
- ផ្ដល់ជូននូវលេខសំអាងរឺមនុស្សសំរាប់ទាក់ទង
- ធ្វើអោយប្រាកដថា បញ្ហារទាំងឡាយនឹងត្រូវបញ្ជូនឡើងយ៉ាងសមរម្យ
- ពន្យល់ពីគំរោងដែលនឹងត្រូវធ្វើជាបន្ទាប់
- ផ្ដល់ជូននូវការឆ្លុះបញ្ចាំងយ៉ាងប្រាកដនិងជាក់លាក់អំពីអ្វីដែលប៉ូលីសអាចនិងមិនអាចធ្វើបានរាប់ទាំងពេលកំណត់ពិតប្រាកដ

### ចាត់ចែងការស៊ើបអង្កេត រឺ គំរោងត្រូវធ្វើ:

- ផ្ដល់ជូននូវការស៊ើបអង្កេត រឺ ពីគំរោងធ្វើយ៉ាងហ្មត់ចត់
- ទទួលត្រួតពិនិត្យឡើងវិញយ៉ាងប្រាកដប្រជានៃការស៊ើបអង្កេតរឺ គំរោងត្រូវធ្វើ ដោយយកមូលដ្ឋានធ្វើការសំរេចចិត្តពីសកម្មភាពដែលត្រូវធ្វើបន្ត រឺក៏ ត្រូវបញ្ចប់រឿងក្ដី

### ជូនដំណឹងដល់ប្រជាជនពីការរីកចំរើននៃការសាកសួរ:

- រៀបចំអោយមាន របៀប, ទីកន្លែងនិងពេលវេលា ដើម្បីនឹងទាក់ទងទៅប្រជាជន

## សំរាប់អ្នកដែលធ្វើខុស, អ្នកជាប់ចោទរឺ អ្នកនៅក្រោមអំណាចអាជ្ញាធរប៉ូលីស, យើងនឹង:

### ដោះស្រាយ តាមកាលៈទេសៈ

- មិនលំអៀងនិងប្រកាន់ខ្ជាប់នូវជំនាញការ
- អនុវត្តចំពោះប្រជាជនទូទៅយ៉ាងយុត្តិធម៌
- អនុញ្ញាត្តអោយប្រជាជនរក្សានូវភាពថ្លៃថ្នូររបស់ពួកគេ
- ប្រតិបត្តិតាមសេចក្ដីតំរូវនៃច្បាប់និងនៃសីលធម៌នៅពេលទទួលធ្វើការស៊ើបអង្កេតរឺរឿងក្ដី

### ផ្ដល់ជូនពត៌មាន:

- ជួយសំរួលពីសិទ្ធិរបស់ប្រជាជន
- ផ្ដល់ដំណឹងដល់ប្រជាជនពីដំណាក់ការដែលត្រូវធ្វើនៅក្នុងរឿងក្ដី នៅពេលដែលសមរម្យ
- ផ្ដល់ជូននូវឯកសារដែលត្រូវការនៅក្នុងគំរោងស្របច្បាប់
- ជួយសំរួលការបើករឿងក្ដីនៅចំណុចនៃពេលដ៏សមរម្យ

Government
of South Australia